ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបិទ
## កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៤

**ថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨**

**ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤**

**នៅទីស្តីការគណៈរដ្ឋមន្ត្រី**

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តមក្នុងកិច្ចប្រជុំនាពេលនេះ!

ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គរបស់យើងបានធ្វើបទបង្ហាញ រួមជាមួយនឹងការពិភាក្សា និងផ្តល់យោបល់យ៉ាងផុលផុស ដែលនាំឱ្យយើងទទួលបាននូវលទ្ធផលគួរជាទីមោទនៈសមស្របទៅនឹងកម្មវត្ថុនៃកិច្ចប្រជុំនាពេលនេះ ដែលខ្ញុំសូមសង្ខេបជូនដូចតទៅ ៖

**ទី១ :** ការអនុម័តជាគោលការណ៍នូវសេចក្តីព្រាងវឌ្ឍនភាព នៃការអនុវត្តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៤។

**ទី២ :** ដាក់ចេញនូវសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៤ សម្រាប់ការអនុវត្តក្នុងឆមាសទី១ ឆ្នាំ២០២៥។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

ទោះបីជាពេលវេលារបស់យើងមានពេលមួយព្រឹកក៏ពិតមែន តែដោយសារមានការចូលរួមយ៉ាងសកម្មពីឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា បានធ្វើឱ្យពេលវេលាដ៏មានតម្លៃរបស់យើងអាចទទួលបាននូវផ្លែផ្កា ហើយដែលខ្ញុំសូមយកឱកាសនេះ សម្តែងនូវការកោតសរសើរដ៏ស្មោះបំផុតជូនសមាជិក សមាជិកានៃអង្គពិធីទាំងមូល។

គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ បានដាក់ចេញនូវវិធានការមួយចំនួន រួមទាំងការបង្កើនការវិនិយោគជាតិ ការចូលរួមសហគមន៍កាន់តែស៊ីជម្រៅ កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីបិទគម្លាតនៃការបង្ការ និងការបង្កើនលទ្ធភាពទទួលបានសន្តិសុខសង្គម និងការថែទាំសុខភាពសម្រាប់ជនងាយរងគ្រោះ ដោយធានាថាធនធាន និងសេវាកម្មត្រូវបានកែសម្រួល និងកំណត់គោលដៅសម្រាប់អ្នកដែលត្រូវការច្រើនបំផុត។

ខ្ញុំសូមអនុញ្ញាតឆ្លៀតឱកាសមុនបិទកិច្ចប្រជុំពេញអង្គរបស់យើង ផ្ដល់ជូននូវចំណាប់អារម្មណ៍បូកសរុបលទ្ធផលជារួមដែលទទួលបានពីកិច្ចប្រជុំនេះដូចខាងក្រោម ៖

១) ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំអនុវត្តផែនការសកម្មភាព រយៈពេល៦ខែចុងឆ្នាំ ២០២៤ ទៅតាមក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៣) សូមកោតសរសើរចំពោះក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានប្រឹងប្រែងចូលរួមអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ និងផែនការយុទ្ធសាស្ត្រជាតិ ទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី ៦ ឆ្នាំ២០២៤-២០២៨។

៤) សូមវាយតម្លៃខ្ពស់ចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានចូលរួមជំរុញឱ្យមានវឌ្ឍនភាពក្នុងការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការផ្ដល់ថវិកា និងការរៀបចំនីតិវិធីប្រើប្រាស់កញ្ចប់ថវិកាជាតិដល់ក្រសួង ស្ថាប័ន និងរាជធានី ខេត្តទាំង២៥។

៥) អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្តសហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការបន្តជំរុញឱ្យមានវឌ្ឍនភាពការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨។

៦) បន្តជំរុញឱ្យមានវឌ្ឍនភាព ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី ៦ ឆ្នាំ២០២៤-២០២៨។

៧) អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្តសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីសិក្សាលើលទ្ធភាពប្រើប្រាស់ អត្ថប្រយោជន៍គាំពារសង្គមក្នុងការគាំទ្រដល់ការងារឆ្លើយតបនឹងការរាលដាលមេរោគអេដស៍ ជាពិសេសការលើកទឹកចិត្តឱ្យប្រជាជនគន្លឹះស្ម័គ្រចិត្តមកធ្វើតេស្តឈាមរកមេរោគអេដស៍អាចចាត់ទុកជាមធ្យោបាយមួយក្នុងការបង្កើនការមកទទួលយកសេវាសុខភាពរួមទាំងការធ្វើតេស្តឈាមរកមេរោគអេដស៍ផងដែរ។

៧) បន្តអន្តរាគមន៍ផ្តោតសំខាន់ លើក្រុមប្រជាជនគន្លឹះ និងយុវជនវ័យ ដើម្បីបង្កើនចំណេះដឹងអំពីមេរោគអេដស៍ ក៏ដូចជាការទទួលបានសេវាបង្ការ និងការធ្វើតេស្តរកមេរោគអេដស៍ និងស្វែងរកវិធីថ្មីៗទៀត ក្នុងការធ្វើការដើម្បីផ្តល់សេវាទាក់ទងនឹងមេរោគអេដស៍ដល់អ្នកដែលមិនទាន់បានទទួលអន្តរាគមន៍ ។

ជាមួយគ្នានេះផងដែរ ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១) អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់ជាតុចូល និង អនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ដើម្បីយកទៅរៀបចំ និងកែសម្រួលសម្រាប់ដាក់ចេញនូវគម្រោងផែនការសកម្មភាពនាពេលខាងមុខ។

២) កសាងសមត្ថភាពស្ថាប័ន សហគមន៍ និងបុគ្គល ដើម្បីពង្រឹងការឆ្លើយតបដោយសហគមន៍ និងកែលម្អការធ្វើសមាហរណកម្មឆ្លើយតបនឹងមេរោគអេដស៍ក្នុងវិស័យសុខាភិបាល និង វិស័យមិនមែនសុខាភិបាល ។

៣) បន្តជំរុញ និង ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គម និងបង្កើតបរិយាកាសអំណោយផលឱ្យក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ បានទទួលសេវាមេរោគអេដស៍ សេវាសុខាភិបាល និងសេវាគាំទ្រផ្នែកច្បាប់ និងសង្គមផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។

៤) បន្តជំរុញការពង្រឹងប្រព័ន្ធជាតិ (Country system) ក្នុងការឆ្លើយតបជា ពហុវិស័យ ចំពោះការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ឈានទៅសម្រេចឱ្យបានក្នុងពេលឆាប់ៗនូវចីរភាពនៃកម្មវិធីអេដស៍នៅកម្ពុជា ។

៥) សូមលើកទឹកចិត្តជូនក្រសួងផែនការ ក្រសួងសុខាភិបាល និង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បន្តធ្វើកិច្ចសហការជំរុញការផ្តល់បណ្ណសមធម៌ដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ឱ្យបានសម្រេច១០០ភាគរយ នៅបំណាច់មធមាសទី១ ឆ្នាំ២០២៥។

៦) បង្កើនអន្តរាគមន៍ស្វែងរកអ្នកផ្ទុកមេរោគអេដស៍ប្រមាណជិត៧ ០០០នាក់ ដែលមិនទាន់បានដឹងពីស្ថាពភាពថាបានផ្ទុកមេរោគអេដស៍ ឱ្យមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍។

៧) បង្កើនតំបន់គ្របដណ្តប់កម្មវិធី PrEP ឱ្យបានទូលំទូលាយ និងឱ្យកាន់តែមានប្រសិទ្ធភាព។ បន្តផ្សព្វផ្សាយការយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់សេវា PrEP ដើម្បីទាក់ទាញអ្នកដែលមិនទាន់បានដឹងឱ្យមកទទួលយកសេវា ពិសេសលើក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ និងក្រុមអ្នកបម្រើសេវាកម្សាន្ត។

៨) បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីទទួលបានជំនួយទាំងសម្ភារ ថវិកា និងបច្ចេកទេស សម្រាប់ចីរភាពកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជាសម្រេចបានជោគជ័យក្នុងការលុបបំបាត់ជំងឺអេដស៍ជាស្ថាពរ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំពេញអង្គដ៏មានសារៈសំខាន់នាពេលនេះ។ តាមរយៈការចូលរួមយ៉ាងសកម្ម ដោយផ្តល់នូវគំនិត យោបល់ល្អៗ និងមានតម្លៃ

នាំឱ្យយើងអាចយកទៅប្រើប្រាស់ក្នុងការកែលម្អការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។

ខ្ញុំសូមសម្តែងនូវការកោតសរសើរផងដែរចំពោះ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានខិតខំរៀបចំកិច្ចប្រជុំពេញអង្គនេះ ឱ្យប្រព្រឹត្តទៅបានដោយរលូន និងសម្រេចបាននូវលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈនាពេលនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ទាំងអស់នូវជ័យមង្គល មហាប្រសើរ សេចក្តីសុខ សេចក្តីចម្រើន ប្រាជ្ញាឈ្លាសវៃ ដើម្បីបន្តភារកិច្ច រួមជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទទួលបានជោគជ័យថ្មីៗបន្ថែមទៀត និងសូមប្រកាសបិទ "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៤**" ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***